ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា
លេខ : ...319/80...ក.ប

សាធារណរដ្ឋប្រជាមានិត កម្ពុជា
ឯករាជ្យ សន្តិភាព សុភមង្គល

ភ្នំពេញ ថ្ងៃទី 14 ខែ តុលា ឆ្នាំ ១៩៨០

# សេចក្តីសម្រេច

របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ស្តីពី
ការបង្កើត គណៈកម្មាធិការកណ្តាលកាកបាទក្រហម នៃ
សាធារណរដ្ឋប្រជាមានិត កម្ពុជា

## ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍

- ដោយអនុលោមតាម សេចក្តីសម្រេចលេខ ០២ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ស្តីពីការ ចាត់តាំង សមាសភាព និងរបៀបរបបធ្វើការ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ។

- ដោយយល់ឃើញថាត្រូវតែជំរុញ ការពិនិត្យពិចារណា និងការធ្វើសកម្មភាពមនុស្សធម៌នៃចលនាកាកបាទក្រហម ដើម្បីបម្រើតម្រូវការសង្គមកិច្ចនៃប្រទេសជាតិ និងផលប្រយោជន៍របស់ប្រជាជន ដើម្បីបម្រើសន្តិភាព មិត្តភាព និងសហប្រតិបត្តិការអន្តរជាតិ ។

- ដោយយោងទៅតាមសំណើរបស់ លោករដ្ឋមន្ត្រី ក្រសួង កសិកម្ម ។

## សេចក្តីសម្រេច

**ប្រការ ១** : បង្កើតគណៈកម្មាធិការកណ្តាលកាកបាទក្រហម នៃសាធារណរដ្ឋប្រជាមានិត កម្ពុជា ដែលមានភារកិច្ច ដូចតទៅ :

- ធ្វើការពិនិត្យពិចារណា រៀបចំគម្រោងស្នើជូនក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា សម្រេចលើបញ្ហាទាំងឡាយណា ដែលទាក់ទងដល់ការធ្វើសកម្មភាព និង ការការពារធនធាននៃចលនាកាកបាទក្រហម ។

- ដឹកនាំការងារ នៃសាខា តាមសាខា បណ្តាខេត្ត បណ្តាក្រុង និង ទីក្រុងនានា ដែល នៅក្រោមចំណុះមជ្ឈិម ដើម្បីអនុវត្តន៍នូវសេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ស្តីពីកាកបាទក្រហម ។

- ធ្វើសហប្រតិបត្តិការជាមួយនឹង គណៈកម្មាធិការកណ្តាលកាកបាទក្រហម នៃសាធារណរដ្ឋប្រជាមានិតនៃប្រទេស ប្រជាមានិតទាំងឡាយ និង គណៈកម្មាធិការកាកបាទក្រហម នៃសាធារណរដ្ឋសង្គមនិយម-វៀតណាម ជាមួយនឹងបណ្តាប្រទេស និង បណ្តាអង្គការអន្តរជាតិដទៃទៀត ក្នុងការពិនិត្យ ពិចារណា និង ការធ្វើសកម្មភាពខាងកាកបាទក្រហម ដោយយល់ព្រមទៅនឹងគោល ប្រយោជន៍នៃបណ្តាប្រទេសដែលពាក់ព័ន្ធនៅតាមបណ្តាមហាស្ថាន និង ដោយគោរព-ប្រតិបត្តិ តាមសេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ស្តីពីកាកបាទក្រហម ។

ក្នុងរយៈកាលអនុវត្តភារកិច្ចទាំងឡាយ គណៈកម្មាធិការ [illegible] នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវរៀបចំឱ្យមានផ្លូវប្រាប់ប្តូរគោលដៅទាំងឡាយ ដែលមានគោលនាំងលើនេះ ។

ប្រការទី ២: គណៈកម្មាធិការ [illegible] នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា រួមមាន : អ្នកតំណាងឱ្យក្រសួងកសិកម្ម, ក្រសួងគមនាគមន៍ - ដឹកជញ្ជូន, ក្រសួងឧស្សាហកម្ម និង ក្រសួងការបរទេស ដែលមានលោកវៃក្រ គង់ សំអុល អនុរដ្ឋមន្ត្រី ក្រសួងកសិកម្ម ធ្វើជាប្រធានគណៈកម្មាធិការនេះ ។ នៅពេលការចាំបាច់ គឺនឹងមានការបន្ថែមសមាសភាពរបស់គណៈកម្មាធិការនេះ ។

ទីស្នាក់ការរបស់គណៈកម្មាធិការ [illegible] នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ស្ថិតនៅក្រសួងកសិកម្ម ដែលត្រូវមានលេខាធិការប្រចាំការជាអចិន្ត្រៃយ៍ មួយរូបទទួលបន្ទុក ។

ប្រការទី ៣ : គណៈកម្មាធិការ [illegible] នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវ[illegible] ពិចារណានូវលក្ខន្តិកៈ ស្តីពីការបោះតាំង និង សកម្មភាពរបស់គណៈកម្មាធិការនេះ ដើម្បីបញ្ជូនជូនក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ប្រកាសឱ្យអនុវត្ត ។

ប្រការទី ៤ : លោកប្រធានមន្ទីរក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា, លោករដ្ឋមន្ត្រី នៃ បណ្តាក្រសួងកសិកម្ម, ក្រសួងគមនាគមន៍ - ដឹកជញ្ជូន, ក្រសួងឧស្សាហកម្ម, ក្រសួងការបរទេស មានភារៈអនុវត្តតាមសេចក្តីសម្រេចនេះ ។

ជ. ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា

ហេង សំរិន

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋមន្ត្រី

លេខ : 116 អ.ន.ក្រ

ភ្នំពេញ ថ្ងៃទី 10 ខែ តុលា ឆ្នាំ ១៩៨៩

# អនុក្រឹត្យ

## ស្តីពីចំណាត់តាំង និង សមត្ថភាពរបស់ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា លេខ ៣១៩ – ៨០ ក.ប ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ១៩៨០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

## សំរេច

**មាត្រា ១** : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ជាស្ថាប័នមួយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានតួនាទីជាលេខាធិការជំនួយការអោយក្រុមប្រឹក្សារដ្ឋមន្ត្រី លើរាល់ការងារគ្រប់គ្រង ដឹកនាំ ការពិនិត្យពិចារណា ការសិក្សា និង ការធ្វើអាជីវកម្មធនធានរបស់ទឹកទន្លេមេគង្គក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចនៃប្រទេសជាតិ និង ផលប្រយោជន៍របស់ប្រជាជន និង បំពេញតួសន្តិភាព – មិត្តភាព – សហប្រតិបត្តិការ ។

**មាត្រា ២** : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានភារកិច្ច និង សិទ្ធិអំណាចដូចតទៅ :

- ធ្វើការពិនិត្យពិចារណា ហើយលើកសំណើជូនក្រុមប្រឹក្សារដ្ឋមន្ត្រីសំរេចលើបញ្ហាទាំងឡាយណាដែលទាក់ទងដល់ការធ្វើអាជីវកម្ម និង ការពារធនធានរបស់ទឹកទន្លេមេគង្គ ។
- រួមសហការដែលនាំ តាមដានបណ្តាផ្នែក បណ្តាខេត្ត – ក្រុងនានា ដើម្បីអនុវត្តនូវសេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីទន្លេមេគង្គ ។
- ធ្វើសហប្រតិបត្តិការជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង គណៈកម្មាធិការជាតិទន្លេមេគង្គនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយនឹងបណ្តាប្រទេស និង អង្គការអន្តរជាតិដទៃទៀត ក្នុងការពិនិត្យពិចារណាការសិក្សា និង ការធ្វើអាជីវកម្មធនធានទឹកទន្លេមេគង្គ ដោយស្របទៅនឹងផលប្រយោជន៍ដ៏ស្មើរបស់បណ្តាប្រទេសដែលស្ថិតនៅតាមមាត់ទន្លេ និង ដោយ

ត្រឹមត្រូវតាមគោលការណ៍គោលនយោបាយរបស់បក្ស និង រដ្ឋ ស្តីពីទេសចរណ៍ ។

មាត្រា ៣ : ចំពោះមុខរចនាសម្ព័ន្ធបាត់តាំងរបស់គណៈកម្មាធិការជាតិទេសចរណ៍មាន :

- មន្ទីរដែលមានឈ្មោះហៅថា លេខាធិការដ្ឋានគណៈកម្មាធិការជាតិទេសចរណ៍ មានឋានៈស្មើនឹងមន្ទីររបស់បណ្តាក្រសួង ។
- បណ្តាអង្គភាពបាត់តាំងផ្សេងទៀតចំណុះមន្ទីរ អាស្រ័យដោយគណៈកម្មាធិការជាតិទេសចរណ៍បង្កើត ។
- ចំពោះក្របខ័ណ្ឌកម្មាភិបាល បុគ្គលិក កម្មករ អាស្រ័យដោយគណៈកម្មាធិការជាតិទេសចរណ៍សំរេចកំណត់ក្រោយពីបានពិភាក្សាឯកភាពជាមួយក្រសួងផែនការ ហើយរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ។
- គណៈកម្មាធិការជាតិទេសចរណ៍ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់គណនេយ្យ - ហិរញ្ញកិច្ចរបស់ស្ថាប័ន ដែលសមមិត្តប្រធានគណៈកម្មាធិការជាតិទេសចរណ៍កម្ពុជាជាអ្នកការ ។ ក្នុងករណីដែលសមមិត្តប្រធានគណៈកម្មាធិការជាតិទេសចរណ៍មានភារកិច្ចដាច់ដោយឡែក តែលើបញ្ហាគណៈកម្មាធិការជាតិទេសចរណ៍នោះ គណៈកម្មាធិការនេះត្រូវបានអនុញ្ញាតអោយបង្កើតគណនេយ្យ ហិរញ្ញកិច្ចដាច់ដោយឡែកផ្ទាល់របស់ខ្លួន ។

មាត្រា ៤ : អនុលោមតាមអនុក្រឹត្យនេះ ប្រធានគណៈកម្មាធិការជាតិទេសចរណ៍មានភារកិច្ចកំណត់ជាក់លាក់ស្តីពីចំណាត់តាំង និង សកម្មភាពរបស់លេខាធិការដ្ឋាន ដើម្បីធានាអោយលេខាធិការដ្ឋានធានាសកម្មភាពត្រឹមត្រូវតាមការកំណត់ និង ទទួលបានផលខ្ពស់ ។

មាត្រា ៥ : គណៈកម្មាធិការជាតិទេសចរណ៍មានប្រធាន ០១ រូប ជាអ្នកដឹកនាំ និង ទទួលខុសត្រូវផ្ទាល់ចំពោះមុខក្រុមប្រឹក្សារដ្ឋមន្ត្រីនូវរាល់ការងារពាក់ព័ន្ធដល់ការពិនិត្យពិចារណា ការសិក្សា និង ការធ្វើអាជីវកម្មធនធានដែនទឹកទេសចរណ៍ ។

បណ្តាសមមិត្តអនុប្រធានគណៈកម្មាធិការជាតិទេសចរណ៍ មានភារកិច្ចជួយសមមិត្តប្រធាននូវការងារដែលបានប្រគល់ជូន ។

គណៈកម្មាធិការជាតិទេសចរណ៍មានសមាជិកតំណាងអោយក្រសួងកសិកម្ម ០១ រូប ក្រសួងឧស្សាហកម្ម ០១រូប ក្រសួងគមនាគមន៍ដឹកជញ្ជូននិងប្រៃសណីយ៍ ០១រូប និងក្រសួងការបរទេស ០១ រូប ។

មាត្រា ៦ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី គណៈកម្មាធិការជាតិទេសចរណ៍កម្ពុជា ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និងបណ្តាក្រសួងមន្ទីរជុំវិញមជ្ឈិម ព្រមទាំងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល :
- ខុទ្ទកាល័យមជ្ឈិមបក្ស
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
- គណៈបាត់តាំងមជ្ឈិម

« ដើម្បីជ្រាបជាពត៌មាន »

- ដូចមាត្រា ៦ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០១៩៩/០៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី ·

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩

## ត្រាស់បង្គាប់

មាត្រា១ : តែងតាំងសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដូចតទៅ :

១– ឯកឧត្តម ឃី តាំងលីម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធាន

២– ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អនុប្រធាន

៣– ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន អនុប្រធាន

៤– ឯកឧត្តម ស៊ិន នីទី អគ្គនាយកក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ អនុប្រធាននៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើនឹងរដ្ឋលេខាធិការ ។

មាត្រា២ : ចំពោះតំណាងក្រសួងពាក់ព័ន្ធ ដែលជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា គឺត្រូវរៀបចំតែងតាំងដោយអនុក្រឹត្យ យោងតាមសំណើរបស់ប្រធាន ។

មាត្រា៣ : ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៤ : រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៥ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩

លេខ : ១៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៩

រដ្ឋលេខាធិការរាជរដ្ឋាភិបាល

សាអ៊ី តាន់

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ. ថ្ងៃទី ៤៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

ជ. ប្រធាន

អនុប្រធាន

ភិរុន ពិសិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ

## របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

********

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៨៩ ស្តីពីចំណាត់តាំង និង សកម្មភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងសមាសភាពថ្មី នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

## សំ រេ ច

****

## ជំពូក ១

## បទបញ្ញត្តិទូទៅ

<u>មាត្រា</u> ១ : អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាព នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងកំណត់បេសកកម្មរបស់ស្ថាប័ន និង មុខងារនៃអគ្គលេខាធិការដ្ឋាន និង បណ្តានាយកដ្ឋាននានា ដែលស្ថិតនៅក្រោមឱវាទនៃគណៈកម្មាធិការនេះ ។

# ជំពូក ២

# បេសកកម្ម និង រចនាសម្ព័ន្ធ

__មាត្រា__ ២ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាហៅកាត់ថា "គជទមក ឬ CNMC" ជាស្ថាប័នជាតិមួយចំណុះរាជរដ្ឋាភិបាលមានតួនាទីជាសេនាធិការ ជំនួយការនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើរាល់ការកសាងនយោបាយទឹក ការរៀបចំយុទ្ធសាស្ត្រ ការងារគ្រប់គ្រង ការថែរក្សា ការសិក្សា ការធ្វើផែនការ ការស្តារ និង ការធ្វើអាជីវកម្មលើធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ជានិរន្តរ៍នៃសេដ្ឋកិច្ចសង្គម និង ហេដ្ឋារចនាសម្ព័ន្ធជាតិ ដើម្បីជាផលប្រយោជន៍ជាតិ និង ប្រជារាស្ត្រ ។

__មាត្រា__ ៣ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានមុខងារ និង ភារកិច្ចដូចតទៅ :

១- ធ្វើការសិក្សាពិនិត្យពិចារណា ដោយលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ សំរេចលើរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងការធ្វើផែនការ ការរៀបចំយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍន៍ ព្រមទាំងការគ្រប់គ្រង និង ថែរក្សាការពារធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធ ក្នុងអាងទន្លេមេគង្គ ។

២- រួមសហការណែនាំ តាមដានបណ្តាផ្នែកនៃក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសំរេចទាំងឡាយរបស់រាជរដ្ឋាភិបាល ស្តីពីទន្លេមេគង្គ ។

៣- ពង្រឹងសហប្រតិបត្តិការ ជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក ជាមួយបណ្តាប្រទេសផ្តល់ជំនួយឯទៀត និង អង្គការអន្តរជាតិផ្សេងៗ ក្នុងការពិនិត្យ ពិចារណា ការសិក្សា និងការអភិវឌ្ឍន៍ ការគ្រប់គ្រង និង ថែរក្សាធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធនឹងទន្លេមេគង្គ អោយបានសមស្របទៅនឹងផលប្រយោជន៍សមរម្យរបស់បណ្តាប្រទេសជាសមាជិក ។

៤- ធ្វើការទំនាក់ទំនង សំរបសំរួលជាមួយគណៈកម្មការទន្លេមេគង្គ និង បណ្តាសហគមន៍ផ្តល់ជំនួយអន្តរជាតិនានា ដើម្បីស្វែងរកទុនជំរុញការសិក្សា និង អភិវឌ្ឍន៍គំរោងអោយបានឆាប់រហ័សទាន់ពេលវេលា និង មានប្រសិទ្ធិភាពខ្ពស់ ។

__មាត្រា__ ៤ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដឹកនាំដោយប្រធាន ០១រូប ថ្នាក់ស្មើនឹងរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល និងមានអនុប្រធានមួយចំនួន ថ្នាក់បរិងទាបស្មើនឹងរដ្ឋលេខាធិការរបស់បណ្តាក្រសួង ជាជំនួយការ ។

មាត្រា ៥ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានសមាជិក :

- ក្រសួង សាធារណការ និង ដឹកជញ្ជូន
- ក្រសួង ធនធានទឹក និង ឧតុនិយម
- ក្រសួង បរិស្ថាន
- ក្រសួង កសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ
- ក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួង ផែនការ
- ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួង អភិវឌ្ឍន៍ជនបទ
- ក្រសួង ទេសចរណ៍

តំណាងអចិន្ត្រៃយ៍នៃក្រសួងជាសមាជិកត្រូវមានថ្នាក់យ៉ាងទាបស្មើនឹងប្រធាននាយកដ្ឋាន ។

មាត្រា ៦ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានគណៈកម្មការប្រតិបត្តិមួយ សំរាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ :-

១- ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

២- បណ្តាអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

៣- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

៤- បណ្តាអគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

មាត្រា ៧ : រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមាន :

- អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការ០១រូបមានថ្នាក់ស្មើនឹងអនុរដ្ឋលេខាធិការរបស់បណ្តាក្រសួង និង មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ មានថ្នាក់ស្មើអគ្គនាយកនៃក្រសួង ។
- បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានរួមមាន :
    - នាយកដ្ឋាន រដ្ឋបាល-ហិរញ្ញវត្ថុ
    - នាយកដ្ឋាន ផែនការ
    - នាយកដ្ឋាន បណ្តាគំរោង
- នាយកដ្ឋាននិមួយៗត្រូវដឹកនាំដោយប្រធាន ០១រូប និងអនុប្រធាន ០១រូប ជាជំនួយការ ហើយមានការិយាល័យចំណុះមួយចំនួនទៀត ។

អង្គការលេខរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

<u>មាត្រា</u> ៨ : ភារកិច្ចរបស់បណ្តាអង្គភាពចែងក្នុងមាត្រា៧ មានដូចតទៅ :

**៨.១ <u>អគ្គលេខាធិការដ្ឋាន</u> :**

- ធ្វើទំនាក់ទំនងសំរបសំរួលជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនិង គណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក លើរាល់សកម្មភាពទាក់ទងនឹងបញ្ហាទន្លេមេគង្គ ។
- រាយការណ៍ និងផ្តល់យោបល់ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។
- សំរបសំរួលរាល់សកម្មភាព និងការងាររបស់គណៈកម្មាធិការជាតិទន្លេមេគង្គ កម្ពុជា ។
- លើកគំរោងកម្មវិធីការងារ ដាក់ជូនគណៈកម្មការទន្លេមេគង្គ ស្របតាមទិសដៅផែនការ នៃការដឹកនាំរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីរកជំនួយ ។
- តាមដាន ណែនាំ និងវាយតំលៃលើផលសំរេច នៃការអនុវត្តន៍រាល់ការងារដែលជាភារកិច្ចរបស់បណ្តាអង្គភាពនៅក្នុងបន្ទុករបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង អង្គភាពនៃស្ថាប័នពាក់ព័ន្ធ ។
- បូកសរុបគ្រប់សកម្មភាព និងគ្រប់សភាពការណ៍នៃការងារ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌ និង ភារកិច្ចរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**៨.២ <u>នាយកដ្ឋាន រដ្ឋបាល-ហិរញ្ញវត្ថុ</u> :**

- ទទួលខុសត្រូវសេវាកម្មទូទៅក្នុងផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ ការផ្គត់ផ្គង់ និង ពតិមាន ។
- ទទួលខុសត្រូវការងារ សំណុំលិខិតឯកសារ លិខិតបទដ្ឋានច្បាប់ ឯកសារសម្ងាត់ ការងារទំនាក់ទំនងរដ្ឋបាលគ្រប់ផ្នែក ការតម្កល់ឯកសារ ការងារសន្តិសុខ-សណ្តាប់ធ្នាប់ និង អនាម័យ ។
- គ្រប់គ្រងមន្ត្រី-បុគ្គលិក-និយោជិត និងអភិវឌ្ឍន៍ធនធានមនុស្ស ដោះស្រាយប្រាក់បៀវត្ស-ប្រាក់ឧបត្ថម្ភផ្សេងៗ ដែលរាជរដ្ឋាភិបាលកំណត់អោយមន្ត្រី-បុគ្គលិក-និយោជិតទាំងនោះ ។
- រៀបចំគំរោងថវិកា គំរោងសំភារៈ និង មធ្យោបាយការងារ ។
- ទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ និង ភ្នាក់ងារហិរញ្ញវត្ថុនៃអង្គការផ្តល់ជំនួយនានា ក្នុងការប្រើប្រាស់ថវិកា ។

- គ្រប់គ្រងអចលនទ្រព្យ-ចលនទ្រព្យ-ទឹក-ភ្លើង របស់អគ្គលេខាធិការដ្ឋាន ។
- ទទួលខុសត្រូវ ការប្រើប្រាស់ និង ការថែទាំកុំព្យូទ័រ ក្នុងអគ្គលេខាធិការដ្ឋាន ។

**៤.៣ <u>នាយកដ្ឋាន ផែនការ</u> :**

- ទទួលខុសត្រូវក្នុងការប្រមូលផ្តុំ ចំរាញ់លទ្ធផល នៃការសិក្សាទាំងឡាយក្នុងប្រទេស និងក្នុងតំបន់អាងទន្លេមេគង្គ ពីធនធានទឹក និងធនធានដទៃទៀតដែលពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយអភិវឌ្ឍន៍រយៈពេលខ្លី-មធ្យម-វែង ស្នើជូនគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សំរេច ។
- ធ្វើផែនការ និង ទទួលខុសត្រូវលើការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សរយៈពេលខ្លី-មធ្យម-វែង ។
- សិក្សាស្រាវជ្រាវ រៀបចំ ណែនាំ ចាត់តាំងអនុវត្តគោលនយោបាយ គោលការណ៍ជាយុទ្ធសាស្ត្រជាក់ស្តែង បទដ្ឋានកម្មវិធីអភិវឌ្ឍន៍ធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធ ក្នុងតំបន់ទន្លេមេគង្គ ។
- ស្រាវជ្រាវ និង ចងក្រងបណ្តាគោលការណ៍ បទដ្ឋានអាទា សំរាប់ធានាដល់កិច្ចការពារធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធ ក្នុងតំបន់ទន្លេមេគង្គ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- ជំនួយការអោយអគ្គលេខាធិការដ្ឋាន ក្នុងកិច្ចសហការជាមួយបណ្តាក្រសួង និងស្ថាប័នដទៃទៀតដែលពាក់ព័ន្ធ និង ធ្វើការទាក់ទងសហប្រតិបត្តិការអន្តរជាតិ ក្នុងក្របខ័ណ្ឌទន្លេមេគង្គ ។
- ទទួលខុសត្រូវក្នុងការប្រមូលផ្តុំ តម្កល់ឯកសារបច្ចេកទេស ដែលពាក់ព័ន្ធទៅលើធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធ ។

**៤.៤ <u>នាយកដ្ឋាន បណ្ណាគំរោង</u> :**

- ប្រមូល ស្រង់ពតិមាន និងមូលដ្ឋានទិន្នន័យពាក់ព័ន្ធធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធ ក្នុងអាងទន្លេមេគង្គ ។
- រៀបចំគ្រប់គ្រងបណ្តាឯកសារផែនទីទាក់ទងនឹងគំរោង ។
- សិក្សាស្រាវជ្រាវ និង រៀបចំគំរោងអភិវឌ្ឍន៍ទន្លេមេគង្គ ។
- សិក្សាស្រាវជ្រាវនូវប្រព័ន្ធពតិមានជលសាស្ត្រ ។

- សិក្សាស្រាវជ្រាវ និង រៀបចំអភិវឌ្ឍន៍ផ្នែកថាមពលវារីអគ្គិសនី ។
- សិក្សាស្រាវជ្រាវ គ្រប់គ្រង និងអភិវឌ្ឍន៍ផ្នែកកសិកម្ម ក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ ។
- សិក្សាកិច្ចអភិវឌ្ឍន៍ផ្នែកទេសចរណ៍ ក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ ។
- សិក្សាស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់ផ្នែកបរិស្ថាន ក្នុងការប្រើប្រាស់ធនធានទឹក និង ធនធានដទៃទៀតដែលពាក់ព័ន្ធនៃអាងទន្លេមេគង្គ ។
- អនុវត្តការងារគ្រប់គ្រង-ត្រួតពិនិត្យ និងរាយការណ៍រាល់សកម្មភាពការងារគំរោងជូនអគ្គលេខាធិការដ្ឋាន ។
- ជំនួយការអោយអគ្គលេខាធិការដ្ឋាន ក្នុងកិច្ចសហការជាមួយ បណ្តាស្ថាប័នពាក់ព័ន្ធ និង ធ្វើសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៩ : ក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិករបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

មាត្រា១០ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិបង្កើតគណនេយ្យមួយ និងប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន ។

មាត្រា១១ : ក្នុងរយៈពេល ៣ខែ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកោះប្រជុំសាមញ្ញម្តងយ៉ាងតិច ។

មាត្រា១២ : ក្នុងរយៈពេល ២សប្តាហ៍ គណៈកម្មការប្រតិបត្តិនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកោះប្រជុំសាមញ្ញម្តងយ៉ាងតិច ។

មាត្រា១៣ : ក្នុងករណីចាំបាច់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាចកោះប្រជុំវិសាមញ្ញ :

- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- គណៈកម្មការប្រតិបត្តិ ។

មាត្រា១៤ : គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិអញ្ជើញប្រធានស្ថាប័នផ្សេង១ ឬ តំណាង ដើម្បីចូលរួមប្រជុំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ឬ ប្រជុំគណៈកម្មការប្រតិបត្តិ ។

## ជំពូក ៣

## អវសានបញ្ញត្តិ

មាត្រា១៥ : ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ការិយាល័យ ចំណុះបណ្តានាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

មាត្រា១៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិអេឡិចត្រូនិចកម្ពុជា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួង និងខេត្តក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា១៨** : អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

សូមជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ប្រធានគណៈកម្មាធិការជាតិអេឡិចត្រូនិចកម្ពុជា

ឃី តាំងលីម

**កន្លែងទទួល** :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ស្ថាប័ន
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ខេត្ត-ក្រុង
- ដូចមាត្រា ១៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ-ឯកសារ

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

ប្រធាន

អនុប្រធាន

ឌិត ទិត្យ

# អង្គការលេខ

## របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា



នស / រកត / ០៤០១ / ០៧០

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើត និងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប

៣៖៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ក្រឹត្យច្បាប់លេខ៣៣ក្រ.ច ចុះថ្ងៃទី០៩ខែមិនាឆ្នាំ១៩៨៧ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានទ្រង់យល់លក្ខន្តិកៈ នៃប្រព័ន្ធឋបនីយជីវមណ្ឌលពិភពលោក ដែលបានអនុម័តនៅក្នុងមហាសន្និបាតទូទៅ របស់អង្គការយូណេស្កូ នៅថ្ងៃទី២០ ដល់២៥ ខែមិនា ឆ្នាំ១៩៩៥
- បានទ្រង់យល់សេចក្តីសំរេចទទួលស្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិ សំរាប់កម្មវិធីមនុស្ស និងជីវមណ្ឌលរបស់អង្គការយូណេស្កូ ក្នុងការបញ្ចូលបឹងទន្លេសាប ទៅក្នុងប្រព័ន្ធឋបនីយជីវមណ្ឌលពិភពលោក នៅក្នុងសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិនៅថ្ងៃទី២៧-២៩ខែតុលាឆ្នាំ១៩៩៧
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០១ ។

# ព្រះរាជក្រឹត្យ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើតបម្រុងជីវមណ្ឌលបឹងទន្លេសាប ដោយផ្អែកលើសារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌បឹងទន្លេសាប ស្របតាមលក្ខន្តិកៈស្តីពីប្រព័ន្ធបម្រុងជីវមណ្ឌលពិភពលោក ។ ការបង្កើតបម្រុងជីវមណ្ឌលបឹងទន្លេសាបនេះ មានគោលបំណងសំខាន់ៗ៣គឺ :

១- អភិរក្សជីវចម្រុះ ទេសភាព សណ្ឋានដី និងប្រព័ន្ធអេកូឡូស៊ី រួមទាំង ធនធានសេនេទិច ប្រភេទរុក្ខជាតិ មច្ឆជាតិ និងសត្វ ព្រមទាំងស្តារឡើងវិញនូវបរិស្ថាន និងជម្រកនៃជីវចម្រុះ។

២- ទ្រទ្រង់ឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពលើប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

៣- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការអនុវត្តគម្រោងបង្ហាញ ការអប់រំបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការអង្កេតតាមដានការប្រែប្រួលបរិស្ថាន ដែលទាក់ទងនឹងការអភិវឌ្ឍ ដោយនិរន្តរភាព ការអភិរក្សនៅក្នុងកម្រិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ ។

## ជំពូកទី២
## ទីតាំងភូមិសាស្ត្រនៃបម្រុងជីវមណ្ឌលបឹងទន្លេសាប

**មាត្រា២.-**

ដើម្បីអនុវត្តនូវគោលបំណងសំខាន់ទាំងបី ដូចបានកំណត់ក្នុងមាត្រា១ បម្រុងជីវមណ្ឌលបឹងទន្លេសាប ត្រូវបែងចែកជាបីតំបន់គឺ តំបន់ស្នូល តំបន់ទ្រនាប់ និងអន្តរៈតំបន់ ។

បម្រុងជីវមណ្ឌលបឹងទន្លេសាបមានព្រំប្រទល់ ខាងលិចទល់នឹងផ្លូវជាតិលេខ៥ ខាងកើតទល់នឹងផ្លូវជាតិលេខ៦ ខាងជើងកំណត់ត្រឹមចំណុចប្រសព្វ នៃផ្លូវជាតិលេខ៥ និងលេខ៦ (13°36'52"N, 103°06'32"E) និងខាងត្បូងកំណត់ត្រឹមឃុំសែប (12°05'06"N, 104°43'39"E) ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ផែនទីព្រំប្រទល់ និងនិយាមការ នៃបម្រុងជីវមណ្ឌលបឹងទន្លេសាប មានក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-**

តំបន់ស្នូលមានបីគឺ :

១- តំបន់ស្នូលព្រែកទាល់ មានទីតាំងស្ថិតនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ហើយមានផ្ទៃក្រឡា ២១.៣៤២ហិកតា ។

២- តំបន់ស្នូលបឹងទន្លេឆ្មារ មានទីតាំងស្ថិតនៅក្នុង ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ហើយ ././.

មានផ្ទៃក្រឡា១៤.៥៦០ហិកតា ។

៣- តំបន់ស្នូលស្ទឹងសែន មានទីតាំងស្ថិតនៅក្នុង ឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ហើយមានផ្ទៃក្រឡា ៦.៣៥៥ហិកតា ។

តំបន់ស្នូលមានសារៈប្រយោជន៍ និងតំលៃស្មើនឹងឧទ្យានជាតិ ឬដែនជម្រកសត្វព្រៃ ដែលកំណត់សម្រាប់ការពារ និងអភិរក្សយូរអង្វែងនូវធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ដើម្បីរក្សាឱ្យបានគង់វង្សនូវព្រៃលិចទឹក មច្ឆាជាតិ សត្វព្រៃគ្រប់ប្រភេទ ប្រព័ន្ធជលសាស្ត្រ និងសោភណភាពនៃធម្មជាតិ ។ តំបន់ស្នូលអនុញ្ញាតឱ្យមានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រ ការអង្កេតតាមដាន និងអេកូទេសចរណ៍ ។ តំបន់នេះមិនអនុញ្ញាតឱ្យមានសកម្មភាពណាមួយ ដែលធ្វើឱ្យរេចរិល ឬ បំផ្លាញជីវចម្រុះឡើយ ។

ឡូត៍នេសាទ ដែលមានតំបន់ស្នូលស្ថិតនៅខាងក្នុង នឹងបន្តធ្វើអាជីវកម្មស្របតាមច្បាប់ជលផល ហើយ ម្ចាស់ឡូត៍នេសាទត្រូវយកចិត្តទុកដាក់ ចូលរួមចំណែកអនុវត្តនូវទិសដៅអភិរក្សយូរអង្វែង ដូចបានកំណត់ខាងលើ ។ ឡូត៍នេសាទទាំងនេះត្រូវទទួលការត្រួតពិនិត្យ និងវាយតម្លៃ ក្នុងរយៈពេល៤ឆ្នាំម្ដង ហើយត្រូវធ្វើកំណែទម្រង់សមស្រប ដើម្បីឱ្យស៊ីសង្វាក់ទៅនឹងទិសដៅការពារ និងអភិរក្សយូរអង្វែងនៃតំបន់ស្នូល ។

ការនេសាទរបស់ប្រជាពលរដ្ឋជាលក្ខណៈគ្រួសារ និងលក្ខណៈសិប្បកម្ម ដែលស្ថិតនៅក្នុងតំបន់ស្នូលខាងក្នុង ត្រូវបន្តអាជីវកម្មស្របតាមច្បាប់ជលផល ដោយមានការរៀបចំជាសហគមន៍នេសាទ ដើម្បីចូលរួមការពារ ស្របតាមស្មារតីព្រះរាជក្រឹត្យ ។

**មាត្រា៤._**

តំបន់ទ្រនាប់មានផ្ទៃក្រឡា៥៤១.៤៨២ហិកតា ដែលមានព្រំប្រទល់ត្រួតស៊ីគ្នា នឹងព្រំប្រទល់ខាងក្រៅនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង នៃបឹងទន្លេសាប ។

តំបន់ទ្រនាប់ជាតំបន់ព័ទ្ធជុំវិញតំបន់ស្នូល ដែលគ្របដណ្ដប់ដោយព្រៃលិចទឹកគ្រប់ប្រភេទ ។ សកម្មភាពរបស់មនុស្សត្រូវបានគ្រប់គ្រងឱ្យបានសមស្រប ដោយស៊ីសង្វាក់នឹងផែនការការពារ និងអភិរក្ស នៃតំបន់ស្នូល ។ សកម្មភាពនេសាទ និងអភិវឌ្ឍន៍ផ្សេងៗនឹងបន្តដំណើរការគ្រប់គ្រងដោយច្បាប់ដែលមានស្រាប់ ដោយឈរលើស្មារតីសហការ និងសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ ។ តំបន់នេះ ក៏ជាកន្លែង សំរាប់ការពិសោធ ស្រាវជ្រាវនូវវិធីសាស្ត្រគ្រប់គ្រងព្រៃលិចទឹក ការនេសាទ កសិកម្ម ការតាំងលំនៅដ្ឋាន ការប្រើប្រាស់ដីធ្លី ធនធានទឹក នាវាចរណ៍ ទេសចរណ៍ ដែលអាចធានានិរន្តរភាព បង្កើនផលិតកម្ម ដោយរក្សាឱ្យបាន នូវគុណភាពបរិស្ថាន និងមច្ឆាជាតិ ។

**មាត្រា៥._**

អន្តរៈតំបន់ជាតំបន់នៅព័ទ្ធជុំវិញតំបន់ទ្រនាប់ មានផ្ទៃដី ៨៩៩.៦០០ហិកតា ស្ថិតនៅចន្លោះព្រំប្រទល់តំបន់ទ្រនាប់ និងផ្លូវជាតិលេខ៥ និងលេខ៦ ។

អន្តរៈតំបន់ជាតំបន់សេដ្ឋកិច្ចចម្រុះ ត្រូវរៀបចំឱ្យបានសមស្របសំដៅធានានិរន្តរភាពកសិកម្ម ការតាំងលំនៅដ្ឋាន និងការប្រើប្រាស់ដីផ្សេងៗ ដោយមិនធ្វើឱ្យមានឥទ្ធិពលអាក្រក់ទៅលើព្រៃលិចទឹក គុណភាពទឹក និងដី នៅក្នុងតំបន់ជុំវិញបឹងទន្លេសាប ។ល។



១៤

# ជំពូកទី៣

## រដ្ឋបាល និងការគ្រប់គ្រង

**មាត្រា៦._**

ដើម្បីជួយសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ក្នុងកិច្ចការពារ និងគ្រប់គ្រងបម្រុងជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវបង្កើតលេខាធិការដ្ឋានបម្រុងជីវមណ្ឌលបឹងទន្លេសាប ដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។ ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន បម្រុងជីវមណ្ឌលបឹងទន្លេសាប ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៧._**

ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការគ្រប់គ្រង ការធ្វើផែនការការពារ និងអភិរក្សតំបន់ស្នូលនៃបម្រុងជីវមណ្ឌលបឹងទន្លេសាប តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដី ផ្អែកលើមាត្រា៣នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៨._**

ការគ្រប់គ្រងតំបន់ទ្រនាប់ និងអន្តរៈតំបន់ ត្រូវអនុវត្តតាមផែនការរបស់ក្រសួងជំនាញពាក់ព័ន្ធ តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ស្របតាមមាត្រា៤ និងមាត្រា៥នៃព្រះរាជក្រឹត្យនេះ ។

# ជំពូកទី៤

## ការកែប្រែព្រំប្រទល់

**មាត្រា៩._**

ព្រំប្រទល់ និងសកម្មភាព នៃតំបន់នីមួយៗនៃបម្រុងជីវមណ្ឌលបឹងទន្លេសាបនេះ អាចនឹងកែប្រែបាន ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែង ដែលទាក់ទងទៅនឹងការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម ការអភិរក្សជីវចម្រុះ និងរក្សាការពារនិរន្តរភាពបរិស្ថាន ដូចចែងក្នុងមាត្រា៣ មាត្រា៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យនេះ ។

ការកែប្រែព្រំប្រទល់ និងសកម្មភាពនៃតំបន់នីមួយៗនៃបម្រុងជីវមណ្ឌលទន្លេសាប ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ដោយមានការយល់ព្រមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ល.ក.

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា១០.–**

បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា១១.–**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។ល។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០០១

**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**

**ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

**បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខ: ៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានី[illegible]ថ្ងៃទី ១៨ ខែ ០៧ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**



**ឈាង តាន់**

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ.......
ចុះថ្ងៃទី.......ខែ.........ឆ្នាំ.....

# ផែនទីបម្រុងជីវមណ្ឌល បឹងទន្លេសាប




- មិរមខេត្ត
- ព្រំប្រទល់ខេត្ត
- ទន្លេ ឬ ស្ទឹង
- អន្តរតំបន់នៅចន្លោះផ្លូវជាតិលេខ៥ និងលេខ៦មានផ្ទៃក្រឡា៨៥៦០០ ហត។ មិនរាប់បញ្ចូលតំបន់ទ្រនាប់។ ចំនួនប្រជាជនក្នុងអន្តរតំបន់មានប្រហែល ១៦៣៩៣៥៨នាក់
- តំបន់ទ្រនាប់មានផ្ទៃក្រឡា៥៤១៨៧២ ហត មិនរាប់បញ្ចូលតំបន់ស្នូល។ ចំនួនប្រជាជនក្នុងតំបន់នេះមានប្រហែល ៦៥៧០០នាក់។
- តំបន់ស្នូលព្រែកទាល់មានផ្ទៃក្រឡា ២១៣៤២ ហត។ មានប្រជាជនឃុំកោះជីវាំងប្រមាណ ១០៣៧៨នាក់ដែលរស់នៅក្បែរតំបន់នេះ
- តំបន់ស្នូលបឹងទន្លេឆ្មារមានផ្ទៃក្រឡា ១៤៥៦០ ហត។ មានប្រជាជនឃុំកាមបាងប្រមាណ ២២១៨នាក់
- តំបន់ស្នូលស្ទឹងសែនមានផ្ទៃក្រឡា ៦៣៥៥ ហត។ មានប្រជាជនឃុំជាក់សណ្តាយប្រមាណ ៦៦៦៩នាក់ដែលរស់នៅក្បែរតំបន់នេះ
- ផ្ទៃទឹកបឹងទន្លេសាប N.T.

រៀបចំដោយ ការិយាល័យផែនទី ក្រសួងបរិស្ថាន
ក្រុមសំរបសំរួលបច្ចេកទេសបឹងទន្លេសាប

# ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យ ស្តីពី
# ការបង្កើត និងគ្រប់គ្រងបម្រុងជីវមណ្ឌលបឹងទន្លេសាប

លេខៈ ចុះថ្ងៃទី ខែ ឆ្នាំ២០០១

| N° | ឈ្មោះទីតាំង និងសញ្ញាសំគាល់ | ដឺក្រេ (Degrees) | | ម៉ែត្រ (UTM) | |
|---|---|---|---|---|---|
| | | រយៈទទឹង (N) | រយៈបណ្តោយ(E) | រយៈទទឹង (N) | រយៈបណ្តោយ(E) |

## I. តំបន់ស្នូល

### ក. តំបន់ស្នូលព្រែកទាល់

| | | | | | |
|---|---|---|---|---|---|
| 1 | ស្ទឹងចាស់ A1 | 13° 13'05" | 103° 36'39" | 1461580 | 349500 |
| 2 | កំពង់ប្រហុក A2 | 13° 13'57" | 103° 38'55" | 1463160 | 353600 |
| 3 | កោះក្អែក A3 | 13° 12'17" | 103° 41'49" | 1460070 | 358805 |
| 4 | ពាក់កន្ទេល A4 | 13° 06'51" | 103° 42'36" | 1450035 | 360154 |
| 5 | បឹងវែង A5 | 13° 03'52" | 103° 37'02" | 1444600 | 350080 |
| 6 | បឹងវែង A6 | 13° 05'57" | 103° 33'42" | 1448450 | 344096 |

### ខ. តំបន់ស្នូលបឹងទន្លេឆ្មារ

| | | | | | |
|---|---|---|---|---|---|
| 1 | បាឡាត់ B1 | 12° 44'30" | 104° 20'57" | 1408568 | 429350 |
| 2 | ពាមបាង B2 | 12° 43'50" | 104° 16'51" | 1407360 | 421924 |
| 3 | B3 | 12° 46'36" | 104° 14'52" | 1412410 | 418380 |
| 4 | B4 | 12° 49'42" | 104° 14'45" | 1418210 | 418154 |
| 5 | B5 | 12° 51'59" | 104° 17'10" | 1422400 | 422564 |
| 6 | B6 | 12° 51'12" | 104° 21'22" | 1420890 | 430142 |

### គ. តំបន់ស្នូលស្ទឹងសែន

| | | | | | |
|---|---|---|---|---|---|
| 1 | C1 | 12° 33'30" | 104° 30'13" | 1388220 | 446090 |
| 2 | C2 | 12° 34'28" | 104° 28'47" | 1390060 | 443504 |
| 3 | C3 | 12° 37'00" | 104° 29'42" | 1394730 | 445173 |
| 4 | C4 | 12° 40'02" | 104° 31'24" | 1400320 | 448259 |
| 5 | C5 | 12° 38'33" | 104° 33'31" | 1397570 | 452097 |
| 6 | C6 | 12° 35'57" | 104° 33'08" | 1392890 | 551346 |

## II. តំបន់ទ្រនាប់

| | | | | | |
|---|---|---|---|---|---|
| 1 | តាមុន D1 | 13°18'18" | 103°14'11" | 1471500 | 309000 |
| 2 | ឡូត៍នេសាទលេខ D2 | 13 ° 18'19" | 103 ° 14'12" | 1460330 | 325730 |
| 3 | សំបូរ D3 | 13°27'41" | 103°28'25" | 1488700 | 334700 |
| 4 | កំពង់ភ្លុក D4 | 13°13'35" | 103°58'39" | 1462300 | 389100 |
| 5 | ម្សាក្រង D5 | 12°52'16" | 104°24'19" | 1424700 | 435400 |
| 6 | ពោធិ D6 | 12°21'39" | 104°40'09" | 1366400 | 464000 |
| 7 | ក្រគរ D7 | 12°32'01" | 104°24'43" | 1385600 | 417100 |
| 8 | មេទឹក D8 | 12°50'42" | 103°51'53" | 1421100 | 3733400 |

## III. អន្តរតំបន់

| | | | | | |
|---|---|---|---|---|---|
| 1 | សែប E1 | 12°05'06" | 104°43'39" | 1332200 | 470300 |
| 2 | កោះថ្កូវ E2 | 12°04'21" | 104°49'34" | 1334500 | 481000 |
| 3 | ជលគីរី E3 | 12°09'27" | 104°52'27" | 1343600 | 486200 |
| 4 | សំរោងសែន E4 | 12°21'17" | 104°52'27" | 1365700 | 486300 |
| 5 | ស្ទឹងសែន E5 | 12 ° 43'05" | 104 ° 43'18" | 1405900 | 469800 |
| 6 | ស្ទោង E6 | 12°56'36" | 104°34'18" | 1438000 | 453500 |
| 7 | សៀមរាប E7 | 13°20'21" | 103°59'49" | 1474800 | 391300 |
| 8 | ស៊ីសុផុន E8 | 13°36'52" | 103°06'32" | 1505900 | 284800 |
| 9 | បាត់ដំបង E9 | 13°05'36" | 103°12'06" | 1448000 | 305000 |
| 10 | ពោធិសាត់ E10 | 12°32'00" | 103°55'23" | 1385400 | 383000 |
| 11 | កំពង់ឆ្នាំង E11 | 12°15'08" | 104°40'20" | 1354300 | 464200 |
| 12 | អណ្ដូងស្វាយ E12 | 12°21'17" | 104°52'47" | 1340600 | 466600 |
| 13 | ព្រៃស្វាយ E13 | 12°41'52" | 103°36'00" | 1406500 | 338800 |

ម.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..៣៤.អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន

## ថបនីយជីវមណ្ឌលបឹងទន្លេសាប

៙❖៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការការពារបរិស្ថាននិង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៣៣ក្រ.ច ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ស្តីពីការបង្កើតនិងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ ៥៧ អនក្រ /បកចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០១ ។

# សម្រេច ៖

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើតលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ឱ្យស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីជួយដល់ការសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និង សហការរវាងក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ អាជ្ញាធរដែនដី និងសង្គមស៊ីវិល ក្នុងកិច្ចការការពារ និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព នៅក្នុងតំបន់ភូមិសាស្ត្រ និងដែនសមត្ថកិច្ច ដែលត្រូវបានប្រគល់ឱ្យ ។

**មាត្រា២.-**

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប មានឋានៈស្មើនាយកដ្ឋាននៃបណ្តាក្រសួង ដែលដឹកនាំដោយលេខាធិការ ១រូប មកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងលេខាធិការរងមួយចំនួន មកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្នុងនោះ លេខាធិការរងមកពីក្រសួងបរិស្ថាន ទទួលបន្ទុកជាលេខាធិការរងអចិន្ត្រៃយ៍ ។

លេខាធិការដ្ឋានមានមន្ត្រីបំរើការងារមកពី ក្រុមសម្របសម្រួលបច្ចេកទេសបឹងទន្លេសាប ដែលកំពុងបំរើការងារឱ្យថបនីយជីវមណ្ឌលបឹងទន្លេសាប ។ ដោយផ្អែកលើផែនការប្រចាំឆ្នាំ លេខាធិការដ្ឋានអាចលើកសំណើជ្រើសរើសសមាជិកបន្ថែមពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**មាត្រា៣.-**

ក្នុងការអនុវត្តការងារសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និងសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ក្នុងកិច្ចការពារ និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ត្រូវឱ្យមានផ្នែកបច្ចេកទេសមួយចំនួន ដែលជាវចនាសម្ព័ន្ធ ជាអាទិ៍ៈ ផ្នែកយុទ្ធសាស្ត្រនយោបាយ និងបណ្តាញការងារ ផ្នែកសិក្សាស្រាវជ្រាវតាមដានត្រួតពិនិត្យ និងទិន្នន័យពត៌មាន ។

ផ្នែកនីមួយៗ មានថ្នាក់ស្មើនឹងការិយាល័យ ដែលដឹកនាំដោយប្រធាន និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**មាត្រា៩.–**

លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប ដែលជាលេខាធិការរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានភារកិច្ច :

- រៀបចំយុទ្ធសាស្ត្រ និងយន្តការ ដើម្បីសំរេចគោលបំណងសំខាន់ៗ របស់ថបនីយជីវមណ្ឌលបឹងទន្លេសាប
- បង្កើតប្រពន្ធ័គ្រប់គ្រងទិន្នន័យ ពត៌មានចម្រុះ សំរាប់ថបនីយជីវមណ្ឌលបឹងទន្លេសាប និង យន្តការផ្លាស់ប្តូរទិន្នន័យពត៌មាន ក្នុងចំណោមស្ថាប័នពាក់ព័ន្ធ
- តាមដានពិនិត្យ វាយតំលៃ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពថបនីយជីវមណ្ឌលបឹងទន្លេសាប ក្នុងរយៈពេលពី ៨ ទៅ ១០ ឆ្នាំម្តង តាមតំរូវការចាំបាច់
- សម្របសម្រួល និងសហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យឡើងវិញ នូវច្បាប់ បទប្បញ្ញត្តិនានាដើម្បីធ្វើអនុសាសន៍លើកស្ទួយការគ្រប់គ្រង ថបនីយជីវមណ្ឌលបឹងទន្លេសាប ប្រកបដោយនិរន្តរភាព
- សម្របសម្រួលរៀបចំប្រព័ន្ធសិក្សាស្រាវជ្រាវ និងឃ្លាំមើលជីវចំរុះ
- បង្កើតបណ្តាញទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្នុងគោលបំណងប្រមូលពត៌មាន សំរាប់បំរើដល់ការធ្វើផែនការស្នើសេចក្តីសំរេចចិត្ត និងការអនុវត្តផែនការអភិរក្ស និងគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប
- រៀបចំកិច្ចប្រជុំ ឬវេទិកាពិភាក្សា ដើម្បីពិភាក្សាលើបញ្ហា ដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ
- សម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងគោលបំណងរៀបចំ លើកគម្រោងផែនការ ដើម្បីរកជំនួយពីរាជរដ្ឋាភិបាល និងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ អំពីសកម្មភាពរបស់លេខាធិការដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាប្រគល់ឱ្យ ។

## ជំពូកទី ២
## អវសានប្បញ្ញត្តិ

**មាត្រា៥._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និង អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

# រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ឆ្នាំ ២០០១

